# វត្តគិរីវង្សាបុប្ផារាម

# WAT KIRY VONGSA BOPHARAM

អាស្រមសមាធិសន្តិភាព
THE PEACE MEDITATION CENTER

100A Cave Hill Road, Leverett, MA 01054 - 9728 U.S.A.
Telephones: 413.367.0280, 413.367.2080
E-Mail: vipassanadhura@gmail.com

## សេចក្តីប្រកាសព័ត៌មាន

### ស្តីពី ការលុបចោលនូវការបើកវគ្គរៀនសមាធិកម្មដ្ឋាន ដោយសារជំងឺរាតត្បាតខូវីត១៩

**គណៈ**កម្មាធិការវត្តមានកិត្តិយសសូមទូលប្រគេន និង ជម្រាបជូន ព្រះករុណាគ្រប់ព្រះអង្គ និងលោក លោកស្រី សីលវន្ត សីលវតី ឧបាសក ឧបាសិកា ពុទ្ធបរិស័ទចំណុះជើងវត្ត បងប្អូនជនរួមជាតិ សប្បុរសជន និង សាធារណជនជ្រាបថា គណៈកម្មាធិការវត្តសម្រេចលុបចោល មិនបានបើកវគ្គរៀនសមាធិកម្មដ្ឋាន នៅថ្ងៃទី២០ ខែមិថុនា ដល់ ថ្ងៃទី០១ ខែកក្កដា ព.ស.២៥៦៤ គ.ស.២០២០ ដូចបានប្រកាស និង គ្រោងទុកនោះទេនៅឆ្នាំនេះ ដោយសារជំងឺរាតត្បាតខូវីត១៩ បណ្តាលឲ្យប៉ះពាល់នៅរដ្ឋម៉ាសាឈូសិត្តស៍ សហរដ្ឋអាមេរិក និង ពិភពលោកទាំងមូល។

**ដើម្បី**សុវត្ថិភាព សុខភាព និងអាយុជីវិតរបស់ព្រះភិក្ខុសង្ឃគ្រប់អង្គ និង ពុទ្ធបរិស័ទ ដែលគង់និងស្នាក់នៅក្នុងអាវាសវត្ត យើងខ្ញុំព្រះករុណាគ្រប់អង្គនិងរូប ដែលជាប្រជាពលរដ្ឋរបស់រដ្ឋម៉ាសាឈូសិត្តស៍ សូមអនុវត្តតាមសេចក្តីប្រកាសរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក និង រដ្ឋម៉ាសាឈូសិត្តស៍ គឺតម្រូវឲ្យមានអនាម័យ និង ស្នាក់នៅក្នុងវត្ត ឬ គេហដ្ឋាន ដើម្បីជួយសង្គ្រោះជីវិតដល់ប្រជាពលរដ្ឋ និង ជួយកាត់បន្ថយនូវជំងឺរាតត្បាតខូវីត១៩ ហេតុនេះ គណៈកម្មាធិការវត្តគិរីវង្សាបុប្ផារាម អាស្រមសមាធិសន្តិភាពអនុលោមតាមសេចក្តីប្រកាសនានា ដូចមានរាយខ្លះៗនៅខាងក្រោម។

**លោក**ប្រធានាធិបតីសហរដ្ឋអាមេរិក ដូណាល់ ត្រាំ (Donald J. Trump) បានប្រកាសដាក់ប្រទេសជាតិឲ្យស្ថិតនៅក្នុងភាពអាសន្ន ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតខូវីត១៩ នៅថ្ងៃសុក្រ ៥រោច ខែផល្គុន ត្រូវនឹងថ្ងៃទី១៣ ខែមីនាកន្លងទៅ។

**លោក**អភិបាលរដ្ឋម៉ាសាឈូសិត្តស៍ ឆាលស៍ បេកឃើ (Charles Baker) បានប្រកាសដាក់រដ្ឋឲ្យស្ថិតនៅក្នុងភាពអាសន្ន នៅថ្ងៃអង្គារ ២រោច ខែផល្គុន ត្រូវនឹងថ្ងៃទី១០ ខែមីនា ឆ្នាំដដែល។

**សូម**លោក លោកស្រី ពុទ្ធបរិស័ទ និងបងប្អូនជនរួមជាតិ មិនបាច់អញ្ជើញមកវត្តទេដូចកាលបរិច្ឆេទខាងលើ និង ក្នុងពេលមានបម្រាមគោចរនោះ។ វត្តអារាមបិទទ្វារដែរនៅក្នុងគ្រាដ៏គ្រោះថ្នាក់នេះ៕

ថ្ងៃព្រហស្បតិ៍ ១រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ទីក្រុងឡេវើរ៉េត, ត្រូវនឹងថ្ងៃទី៧ ខែឧសភា គ.ស.២០២០
**លេខាធិការដ្ឋាន**